



# សញ្ញាណទូទៅនៃការចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុន

ខែកម្ភៈ ឆ្នាំ2019
ក្រសួងយុត្តិធម៌ប្រទេសជប៉ុន
វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
សាស្ត្រាចារ្យច្បាប់
ហ៊ីរ៉ូមីឈិ អូនីស៊ី

February 2019
Hiromichi Onishi
Professor
International Cooperation Department
Research and Training Institute
Ministry of Justice of Japan

# ការចុះបញ្ជីជូនដំណឹងជាមុន

ការចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុនគឺជា

- ការចុះបញ្ជីជូនដំណឹងជាមុនគឺជា···ការចុះបញ្ជីដែលធ្វើឡើងដោយផ្អែកលើការផ្ដុកផ្ដាក់របស់ក្រឡាបញ្ជីនៃតុលាការដែលទទួលបណ្ដឹងនៅក្នុងករណីបណ្ដឹងទាមទារឲ្យធ្វើបដិទានការចុះបញ្ជី ឬ ទាមទារឲ្យលុបចោលការចុះបញ្ជី ដោយសារការលុបចោលមូលហេតុនៃការចុះបញ្ជី ឬ មោឃភាពមូលហេតុនៃការចុះបញ្ជីត្រូវបានដាក់ ដើម្បីព្រមានដល់តតិយជនអំពីរឿងនេះ និងជៀសវៀងការខូចខាតដែលមិនអាចស្មានជាមុន
- ជាប្រភេទនៃការចុះបញ្ជីត្រៀមជាមួយនឹងការចុះបញ្ជីបណ្ដោះអសន្ន
- មានប្រភពនៅក្នុងច្បាប់បារាំង

# ការចុះបញ្ជីជូនដំណឹងជាមុន

បញ្ញត្តិស្តីពីការចុះបញ្ជីជូនដំណឹងជាមុននៅក្នុងច្បាប់ចាស់ស្តីពីការចុះបញ្ជីអចលនវត្ថុនៃប្រទេសជប៉ុន

- ច្បាប់ចាស់ស្តីពីការចុះបញ្ជីអចលនវត្ថុ (ច្បាប់ឆ្នាំ1960 លេខ536)
- មាត្រា 3 (ការចុះបញ្ជីជូនដំណឹងជាមុន)
- ការចុះបញ្ជីជូនដំណឹងជាមុនអាចធ្វើឡើងក្នុងករណីដែលមានបណ្តឹងទាមទារឲ្យលុបចោលការចុះបញ្ជី ឬ ផ្ទើបដិទានការចុះបញ្ជីដោយផ្អែកលើមោឃភាព ឬ ការលុបចោលមូលហេតុនៃការចុះបញ្ជី។ ប៉ុន្តែ បណ្តឹងដោយផ្អែកលើការលុបចោលមូលហេតុនៃការចុះបញ្ជីអាចធ្វើបានតែក្នុងករណីដែលការលុបចោលនោះ អាចតតាំងនឹងតតិយជនសុចរិតបាន។

# ការចុះបញ្ជីជូនដំណឹងជាមុន

បញ្ញត្តិស្ដីពីការចុះបញ្ជីជូនដំណឹងជាមុននៅក្នុងច្បាប់ចាស់ស្ដីពីការចុះបញ្ជីអចលនវត្ថុនៃប្រទេសជប៉ុន

- មាត្រា34 ( ការផ្ទុកផ្ដាក់ឲ្យចុះបញ្ជីជូនដំណឹងជាមុន )
- ចំពោះការចុះបញ្ជីជូនដំណឹងជាមុន ក្រឡាបញ្ជីតុលាការនៃតុលាការដែលទទួលពាក្យបណ្ដឹងដែលបញ្ញត្តក្នុងមាត្រា3 ត្រូវតែភ្ជាប់នូវឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬសេចក្ដីសង្ខេបនៃពាក្យបណ្ដឹងជាមួយលិខិតផ្ទុកផ្ដាក់ ហើយផ្ទុកផ្ដាក់ទៅការិយាល័យចុះបញ្ជី ដោយឆន្ទានុសិទ្ធិ និងដោយគ្មានការយឺតយ៉ាវ។

# ការចុះបញ្ជីជូនដំណឹងជាមុន

បញ្ញត្តិស្តីពីការចុះបញ្ជីជូនដំណឹងជាមុននៅក្នុងច្បាប់ចាស់ស្តីពីការចុះបញ្ជីអចលនវត្ថុនៃប្រទេសជប៉ុន

- មាត្រា145 ( នីតិវិធីនៃការលុបការចុះបញ្ជីជូនដំណឹងជាមុន )
- 1. ប្រសិនបើមានសេចក្តីសម្រេចលើកចោលបណ្តឹងដែលបានកំណត់ក្នុងមាត្រា3 ឬ សេចក្តីសម្រេចស្ថាពរដែលប្រកាសថា បុគ្គលដែលបានដាក់ពាក្យបណ្តឹងនោះចាញ់ក្តី ឬ មានការដកពាក្យបណ្តឹង ឬ មានការបោះបង់ចោលការទាមទារ ឬ មានការសះជាចំពោះកម្មវត្ថុនៃការទាមទារ ក្រឡាបញ្ជីតុលាការនៃសាលាដំបូងត្រូវភ្ជាប់នូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ សេចក្តីសង្ខេបនៃសេចក្តីសម្រេច ឬ ឯកសាររបស់ក្រឡាបញ្ជីតុលាការដែលបញ្ជាក់អំពីការដកពាក្យបណ្តឹង ការលះបង់ការទាមទារ ឬ ការសះជា ជាមួយលិខិតផ្ទុកផ្តាក់ ហើយផ្ទុកផ្តាក់ឲ្យការិយាល័យចុះបញ្ជីលុបការចុះបញ្ជីជូនដំណឹងជាមុន។

# ការចុះបញ្ជីជូនដំណឹងជាមុន

បញ្ញត្តិស្តីពីការចុះបញ្ជីជូនដំណឹងជាមុននៅក្នុងច្បាប់ចាស់ស្តីពីការចុះបញ្ជីអចលនវត្ថុនៃប្រទេសជប៉ុន

- មាត្រា145 ( នីតិវិធីលុបការចុះបញ្ជីជូនដំណឹងជាមុន )
- 2. បញ្ញត្តិនៃកថាខណ្ឌខាងលើត្រូវយកមកអនុវត្តដូចគ្នាផងដែរ ប្រសិនបើមានការដាក់ឯកសារដែលបញ្ជាក់អំពីការលះបង់សិទ្ធិទាមទារឲ្យលុបចោល ឬ ធ្វើបដិទានការចុះបញ្ជីស្ថាពរ ដោយផ្អែកលើលិខិតដែលមានអានុភាពដូចនឹងសាលក្រមស្ថាពរនៃបណ្តឹងដែលកំណត់ក្នុងមាត្រា3 ការសះជា សន្ទានកម្ម ឬ សាលក្រមស្ថាពរផ្សេងទៀត។ នៅក្នុងករណីនេះ "ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ សេចក្តីសង្ខេបនៃសេចក្តីសម្រេច ឬ ឯកសាររបស់ក្រឡាបញ្ជីតុលាការដែលបញ្ជាក់អំពីការដកពាក្យបណ្តឹង ការលះបង់ការទាមទារ ឬ ការសះជា "ដែលលើកឡើងនៅក្នុងកថាខណ្ឌទី១ ត្រូវជំនួសថា "ឯកសារនោះបានដាក់"។
- 3  ប្រសិនបើមានការលុបចោល ឬ ធ្វើបដិទានការចុះបញ្ជីដោយផ្អែកលើការលុបចោល ឬ មោឃភាពមូលហេតុនៃការចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវលុបការចុះបញ្ជីជូនដំណឹងជាមុន។

# ការចុះបញ្ជីជូនដំណឹងជាមុន

## និយមន័យនៃការចុះបញ្ជីជូនដំណឹងជាមុននៅប្រទេសជប៉ុន

- អានុភាពនៃជំនឿទុកចិត្តដោយការបង្ហាញជាសាធារណៈនៃការចុះបញ្ជី···គោលការណ៍នៃជំនឿទុកចិត្តដោយការបង្ហាញជាសាធារណៈ គឺជាការផ្តល់ការការពារទៅលើអ្នកធ្វើប្រតិបត្តិការជំនួញដែលបានជឿជាក់ទៅលើការបង្ហាញជាសាធារណៈ ហើយការការពារនោះដូចគ្នាទៅនឹងស្ថានភាពនៃសិទ្ធិតាមការបង្ហាញជាសាធារណៈ ក្នុងករណីដែលការបង្ហាញជាសាធារណៈមានភាពខុសគ្នាពីស្ថានភាពនៃសិទ្ធិពិតប្រាកដ។
- ការចុះបញ្ជីអចលវត្ថុនៅប្រទេសជប៉ុន···គ្មាន



# ការចុះបញ្ជីជូនដំណឹងជាមុន

## និយមន័យនៃការចុះបញ្ជីជូនដំណឹងជាមុននៅប្រទេសជប៉ុន

- ការចុះបញ្ជីរបស់តតិយជនដែលចូលទៅក្នុងទំនាក់ទំនងប្រតិបត្តិការជំនួញដោយបានជឿជាក់ទៅលើការចុះបញ្ជីបច្ចុប្បន្នអាចប្រែប្រួល ដោយសារពាក្យបណ្ដឹងទាមទារឲ្យលុបការចុះបញ្ជី ឬក៏ការធ្វើបដិទានការចុះបញ្ជី ដែលបានធ្វើឡើងដោយម្ចាស់សិទ្ធិពិតប្រាកដ ត្រូវបានទទួលស្គាល់ ក្នុងករណីនេះតតិយជននោះមិនត្រូវបានការពារទេ ដូចជា សិទ្ធិដែលបានធ្វើលទ្ធកម្មរួចហើយត្រូវបានយកទៅវិញ ឬ ហ៊ីប៉ូតែកត្រូវក្លាយជាហ៊ីប៉ូតែកលំដាប់ក្រោយ។



# ការចុះបញ្ជីជូនដំណឹងជាមុន

លក្ខខណ្ឌនៃការចុះបញ្ជីជូនដំណឹងជាមុននៅប្រទេសជប៉ុន

- មោឃភាព ឬ ការលុបចោលមូលហេតុនៃការចុះបញ្ជី

- ករណីមោឃភាព ឬ ការលុបចោលមូលហេតុនៃការចុះបញ្ជីដែលបានសរសេរជាមូលហេតុនៃការចុះបញ្ជី
- ករណីនត្ថិភាព ឬ គ្មានការកើតឡើងនូវសកម្មភាពគតិយុត្តដែលក្លាយជាមូលហេតុនៃការចុះបញ្ជី
- ឧ) ករណីដែលការចុះបញ្ជីផ្ទេរត្រូវបានធ្វើឡើងដោយផ្អែកតាមកិច្ចសន្យាលក់ទិញដោយលិខិតក្លែងក្លាយ ទាំងដែលគ្មានអង្គហេតុនៃការលក់ទិញទាល់តែសោះ។

# ការចុះបញ្ជីជូនដំណឹងជាមុន

## លក្ខខណ្ឌនៃការចុះបញ្ជីជូនដំណឹងជាមុននៅប្រទេសជប៉ុន

- ករណីដែលអាចយកមោឃភាព ឬ ការលុបចោលទៅតតាំងចំពោះតតិយជនសុចរិតបាន

- មោឃភាពដោយខ្វះសមត្ថភាពខាងធន្ទះ･･･○
- មោឃភាពដោយភាន់ច្រឡំសារជាតុសំខាន់ (CC95) ･･･○
- មោឃភាពដោយផ្ទុយនឹងបញ្ញត្តិនៃការអនុវត្តដោយបង្ខំ･･･○
- មោឃភាពដោយផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ (CC90) ･･･○
- ការលុបចោលដោយអនីតិជន (CC5.2) ･･･○
- ការលុបចោលដោយអ្នកអាណាព្យាបាលទូទៅ ហិតូបត្ថម្ភកៈ អ្នកជំនួយ (CC9, 13.4, 17.4) ･･･○
- ការលុបចោលដោយការគំរាមកំហែង (CC96.1) ･･･○

# ការចុះបញ្ជីជូនដំណឹងជាមុន

(យោង) ករណីកម្ពុជា

- ករណីដែលអាចយកមោឃភាព ឬ ការលុបចោលទៅតតាំងនឹងតតិយជនសុចរិតបាន

- ការលុបចោលដោយខ្វះសមត្ថភាពខាងធន្ទះ (CC14) ･･･〇
- ការលុបចោលដោយការភាន់ច្រឡំ (CC346) ･･･〇
- ការលុបចោលដោយអំពើកេងយកចំណេញហួសហេតុ (CC351) ･･･〇
- មោឃភាពដោយផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ (CC354.1.A) ･･･〇
- មោឃភាពដោយផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ (CC354.1.B) ･･･〇
- ការលុបចោលដោយអនីតិជន (CC18) ･･･〇
- ការលុបចោលដោយអ្នកអាណាព្យាបាលទូទៅ ហិតូបត្ថម្ភកៈ (CC26, 30) ･･･〇
- ការលុបចោលដោយការគំរាមកំហែង (CC350) ･･･〇

# ការចុះបញ្ជីជូនដំណឹងជាមុន

លក្ខខណ្ឌនៃការចុះបញ្ជីជូនដំណឹងជាមុននៅប្រទេសជប៉ុន

- ករណីដែលអាចយកមោឃភាព ឬ ការលុបចោលទៅតតាំងចំពោះតតិយជនសុចរិតបាន

- មោឃភាពដោយបឋបនីយផ្លូវចិត្ត (CC93) ･･･ ×
- មោឃភាពដោយការបង្ហាញឆន្ទៈមិនពិតដែលធ្វើឡើងដោយការឃុបឃិត (CC94) ･･･ ×
- ការលុបចោលដោយការឆបោក (CC96) ･･･ ×
- ការលុបចោលដោយអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍ (CC424.1) ･･･ ×
- គោលការណ៍ច្បាប់នៃរូបភាពខាងក្រៅនៃសិទ្ធិ (CC94.2 អនុវត្តប្រដូច)･･･ ×

# ការចុះបញ្ជីជូនដំណឹងជាមុន

## (យោង) ករណីកម្ពុជា

- ករណីដែលអាចយកមោឃភាព ឬ ការលុបចោលទៅតតាំងនឹងតតិយជនសុចរិតបាន

- មោឃភាពដោយបបនីយផ្លូវចិត្ត (CC352) ･･･×
- មោឃភាពដោយបង្ហាញឆន្ទៈមិនពិត (CC353) ･･･×
- ការលុបចោលដោយការឆបោក (CC347) ･･･×
- ការលុបចោលដោយព័តមានមិនពិត (CC348) ･･･×
- ការលុបចោលដោយការរំលោភបំពានលើស្ថានភាព (CC349) ･･･×
- ការលុបចោលដោយអំពីដែលនាំឲ្យខូចខាតផលប្រយោជន៍ (CC428) ･･･×
- គោលការណ៍ច្បាប់នៃរូបភាពខាងក្រៅនៃសិទ្ធិ (CC353.2 អនុវត្តប្រដូច) ･･･×

# ការចុះបញ្ជីជូនដំណឹងជាមុន

## លក្ខខណ្ឌនៃការចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុន

- ករណីដែលអាចយកមោឃភាព ឬ ការលុបចោលទៅតតាំងនឹងតតិយជនសុចរិតបាន
- ការរំលាយកិច្ចសន្យា (CC545)
- គោលគំនិតដែលបកស្រាយថា ផ្អែកតាមរយៈការរំលាយកិច្ចសន្យា កិច្ចសន្យានឹងត្រូវមោឃភាពដោយប្រតិសកម្ម ･･･○
- គោលគំនិតដែលបកស្រាយថា តតិយជនសុចរិតដែលចូលរួមក្នុងទំនាក់ទំនងប្រតិបត្តិការជំនួញមុនពេលរំលាយកិច្ចសន្យា ពុំទទួលរងការខូចខាតដែលមិនអាចស្មានទុកជាមុន ហើយតតិយជនដែលចូលរួមក្នុងទំនាក់ទំនងប្រតិបត្តិការជំនួញក្រោយពេលរំលាយ ត្រូវឈរលើទំនាក់ទំនងនៃការតតាំងរវាងការទទួលបានសិទ្ធិប្រត្យក្ស និង តតិយជនដែលធ្វើលទ្ធិកម្មសិទ្ធិប្រត្យក្ស･･･×

# ការចុះបញ្ជីជូនដំណឹងជាមុន

(ជំនួយ) ករណីកម្ពុជា

- ករណីដែលមោឃភាព ឬ លុបចោលដែលអាចតតាំងនឹងតតិយជនសុចរិតបាន

- រំលាយកិច្ចសន្យា (ចាប់ពី CC407)
- គោលគំនិតដែលបកស្រាយថាកិច្ចសន្យាមោឃភាពដោយប្រតិសកម្ម តាមការរំលាយកិច្ចសន្យា…○
- គោលគំនិតដែលបកស្រាយថា តតិយជនសុចរិតដែលចូលក្នុងទំនាក់ទំនងពាណិជ្ជកម្មមុនពេលការរំលាយពុំទទួលរងការខូចខាតដែលមិនអាចស្មានទុកជាមុន ហើយតតិយជនដែលចូលក្នុងទំនាក់ទំនងពាណិជ្ជកម្មក្រោយពេលរំលាយ ត្រូវឈរលើទំនាក់ទំនងនៃការតតាំងរវាងការទទួលបានសិទ្ធិប្រត្យក្សនិង តតិយជនដែលធ្វើលទ្ធិកម្មសិទ្ធិប្រត្យក្ស…×

# ការចុះបញ្ជីជូនដំណឹងជាមុន

## លក្ខខណ្ឌនៃការចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុន

- ប្រសិនបើមានការដាក់បណ្តឹងទាមទារឲ្យលុបចោល ឬ ស្តារការចុះបញ្ជី
- ត្រូវតែជាបណ្តឹងទាមទារឲ្យលុបចោលការចុះបញ្ជី ឬ ស្តារការចុះបញ្ជាអំពីសិទ្ធិ
- ជាការចុះបញ្ជីចម្បងក៏បាន ឬ ចុះបញ្ជីបណ្តោះអាសន្នក៏បាន
- មានវិវាទ ប្រសិនបើអាចជំនួសការទាមទារឲ្យលុបការចុះបញ្ជី ទៅជាការទាមទារឲ្យចុះបញ្ជីផ្ទេរទៅម្ចាស់សិទ្ធិពិតប្រាកដ
- ការដាក់បណ្តឹងមិនកម្រិតតែករណីដែលត្រូវបានទាមទារចម្បងនោះទេ ករណីដែលត្រូវបានទាមទារបញ្ចូលគ្នានៃការទាមទារត្រៀម ឬ ទាមទារជម្រើស, ករណីត្រូវបានទាមទារដោយបន្ថែម ឬ ផ្លាស់ប្តូរដោយជំនួស, ករណីដែលត្រូវបានទាមទារដោយបណ្តឹងតប ក៏អាចធ្វើបានដែរ។

# ការចុះបញ្ជីជូនដំណឹងជាមុន

អានុភាពនៃការចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុន

- គ្មានបញ្ញត្តជាពាក្យពេចន៍ច្បាស់លាស់ក្នុងច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុចាស់

- វាមានអានុភាពត្រឹមតែជាការព្រមានតាមភាពជាក់ស្តែង អំពីបណ្តឹងកំពុងដំណើរកាល ទៅកាន់តតិយជនសុចរិតដែលមានបំណងចូលទៅក្នុងទំនាក់ទំនងពាណិជ្ជកម្មលើអចលនវត្ថុនោះ។

- អានុភាពតតាំង…×
- អានុភាពរក្សាការពារលំដាប់…×
- អានុភាពរក្សាការពារសិទ្ធិ…×

# ការចុះបញ្ជីជូនដំណឹងជាមុន

អានុភាពនៃការចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុន

- នៅក្នុងករណីដែលដើមចោទបានឈ្នះបណ្ដឹងទាមទារឲ្យលុបចោល ឬ ស្ដារការចុះបញ្ជី ការលុបចោលការចុះបញ្ជីរបស់តតិយជនដែលបានទទួលក្រោយការចុះបញ្ជីជូនដំណឹងជាមុន ត្រូវធ្វើឡើងដោយការដាក់ពាក្យសុំរួមគ្នារវាងដើមចោទ និងតតិយជន ហើយបើមិនបានទទួលការសហការពីតតិយជនទេ នោះត្រូវឡើងដោយផ្អែកលើសាលក្រមបង្គាប់ឲ្យលុបចោល ។

- ចំពោះមូលហេតុនៃមោឃភាព ឬ លុបចោល ត្រូវបានគេបកស្រាយថា មិនអាចសន្មតថាតតិយជនទុច្ចរិត ឬ សុចរិតដោយមានកំហុសបានទេ។

# ការចុះបញ្ជីជូនដំណឹងជាមុន

## គម្រូនៃការសរសេរអំពីការចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុន

- ការចុះបញ្ជីជូនដំណឹងជាមុនអំពីការលុបចោលកម្មសិទ្ធិ

| ផ្នែកសិទ្ធិ (ខណ្ឌ ក)　　(ចំណុចអំពីកម្មសិទ្ធិ) | | | |
|---|---|---|---|
| លេខលំដាប់ | គោលបំណងនៃការចុះបញ្ជី | ថ្ងៃខែឆ្នាំទទួល･លេខទទួល | ចំណុចអំពីកម្មសិទ្ធិករ និង ផ្សេងៗ |
| 1 | រក្សាកម្មសិទ្ធិ | ថ្ងៃទី5 ខែ6 ឆ្នាំ2017<br>លេខទី00000 | កម្មសិទ្ធិករ 1-1-1, Kasumigaseki, Chiyoda-ku<br>HOMU Taro |
| 2 | ផ្ទេរកម្មសិទ្ធិ | ថ្ងៃទី20 ខែ6 ឆ្នាំ2017<br>លេខទី00000 | មូលហេតុ លក់ទិញចុះថ្ងៃទី7 ខែ6 ឆ្នាំ2017<br>កម្មសិទ្ធិករ 1-1-2, Kasumigaseki, Chiyoda-ku<br>TOKI Jiro |
| 3 | ចុះបញ្ជីជូនដំណឹងជាមុនអំពីការលុបចោលកម្មសិទ្ធិលេខ2 | ថ្ងៃទី28 ខែ2 ឆ្នាំ2018<br>លេខទី00000 | មូលហេតុ ការដាក់បណ្ដឹងទៅសាលាដំបូង○○នៅថ្ងៃទី28 ខែ2 ឆ្នាំ2018 |
| 4 | លុបចោកម្មសិទ្ធិលេខ2 | ថ្ងៃទី28 ខែ2 ឆ្នាំ2019<br>លេខទី00000 | មូលហេតុ ភាន់ច្រឡំ |
| 5 | លុបចោលការចុះបញ្ជីជូនដំណឹងជាមុនលេខ3 | | ការចុះបញ្ជីថ្ងៃទ2 ខែ2 ឆ្នាំ2019 ដោយការលុបកម្មសិទ្ធិលេខ2 |

# ការចុះបញ្ជីជូនដំណឹងជាមុន

នីតិវិធីចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុន

- ក្រឡាបញ្ជីតុលាការនៃតុលាការដែលបានទទួលបណ្ដឹងទាមទារឲ្យលុបចោល ឬ ស្ដារការចុះបញ្ជីដោយសារមោឃភាព ឬ លុបចោលមូលហេតុនៃការចុះបញ្ជី ត្រូវផ្ដើកផ្ដាក់ឲ្យចុះបញ្ជីជូនដំណឹងជាមុន។
- ត្រូវពិនិត្យជាលក្ខណៈទម្រង់លើការអះអាងរបស់ដើមចោទនៅក្នុងពាក្យបណ្ដឹង
- ប្រសិនបើមានការបារម្ភអំពីការប្រើប្រាស់សិទ្ធិដោយបំពាន គឺតម្រូវឲ្យដើមចោទផ្លាស់ប្ដូរការសរសេរពាក្យបណ្ដឹង ដោយយោងតាមការពិនិត្យពាក្យបណ្ដឹង

# ការចុះបញ្ជីជូនដំណឹងជាមុន

នីតិវិធីនៃការលុបចោលការចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុន

- ប្រសិនបើបណ្តឹងបានបញ្ចប់ដោយបាត់ប្រយោជន៍ចំពោះដើមចោទ
- ប្រសិនបើឯកសារដែលបញ្ជាក់អំពីការបោះបង់ចោលការទាមទារឲ្យលុបចោល ឬ ស្តារការចុះបញ្ជីចូលជាស្ថាពរ ដោយសាលក្រមស្ថាពរជាអាទិ៍ ត្រូវបានដាក់ទៅតុលាការ

⇩

- ក្រឡាបញ្ជីតុលាការនៃតុលាការជំនុំជម្រះលើកទី1 ត្រូវផ្ទាក់ផ្តាក់ឲ្យលុបចោលការចុះបញ្ជីជូនដំណឹងជាមុនដោយគ្មានការយឺតយ៉ាវ

# ការចុះបញ្ជីជូនដំណឹងជាមុន

នីតិវិធីនៃការលុបចោលការចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុន

- ប្រសិនបើបណ្តឹងបានបញ្ចប់ដោយមានប្រយោជន៍ចំពោះដើមចោទ

- បើសិនជាបានចុះបញ្ជីលុបចោល ឬ ស្តារការចុះបញ្ជី ដោយផ្អែកលើមោឃភាព ឬ លុបចោលមូលហេតុនៃការចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវលុបចោលការចុះបញ្ជីជូនដំណឹងជាមុនដោយឆន្ទានុសិទ្ធិ។

# ការចុះបញ្ជីជូនដំណឹងជាមុន

## បញ្ហានៃការចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុន

- ទោះបីជាបណ្តឹងបានបញ្ចប់ដោយមានប្រយោជន៍ចំពោះដើមចោទក៏ដោយ ក៏ដើមចោទមិនលុបចោលការចុះបញ្ជីដោយផ្អែកលើសាលក្រមស្ថាពរ ហើយការចុះបញ្ជីជូនដំណឹងជាមុននៅតែបន្សល់ទុក
- ក្រោយពីបានទទួលការផ្ទេរកម្មសិទ្ធិ ដើមចោទដែលជាកម្មសិទ្ធិករនៃអចលនវត្ថុបានដាក់បណ្តឹងទាមទារឲ្យលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ចំពោះចុងចម្លើយដែលបានបង្កើតហ៊ីប៉ូតែក មុន និង ក្រោយការដាក់ពាក្យសុំលក់អចលនវត្ថុនោះ
- ចុះបញ្ជីជូនដំណឹងជាមុនដើម្បីសន្សំសោហ៊ុយចាត់ចែងបណ្តោះអាសន្នហាមឃាត់ការចាត់ចែង
- ការចុះបញ្ជីជូនដំណឹងជាមុនពុំមានអានុភាពរក្សាការពារលំដាប់ និង រក្សាការពារសិទ្ធិនោះទេ ហេតុនេះវាមានអត្ថន័យតិចតួចនៃការទទួលស្គាល់ បន្ថែមពីលើការចុះបញ្ជីបណ្តោះអាសន្ន និង ការចុះបញ្ជីចាត់ចែងបណ្តោះអាសន្ន

# ការចុះបញ្ជីជូនដំណឹងជាមុន

## ការបញ្ឈប់ការចុះបញ្ជីជូនដំណឹងជាមុននៅជប៉ុន

- មានការរិះគន់ខ្លាំងអំពីការប្រើប្រាស់ក្នុងគោលបំណងរារាំងការអនុវត្ត
- ការចុះបញ្ជីជូនដំណឹងជាមុនពុំមានអានុភាពរក្សាការពារលំដាប់ និង រក្សាការពារសិទ្ធិនោះទេ ហេតុនេះវាមានអត្ថន័យតិចតួចនៃការទទួលស្គាល់ បន្ថែមពីលើការចុះបញ្ជីបណ្ដោះអាសន្ន និង ការចុះបញ្ជីចាត់ចែងបណ្ដោះអាសន្ន
- នៅក្នុងបណ្ដឹងទាមទារឲ្យលុបចោល ឬ ស្ដារការចុះបញ្ជី ការចាត់ចែងបណ្ដោះអាសន្នត្រូវប្រើប្រាស់ច្រើន ហើយតាមរយៈការចុះបញ្ជីចាត់ចែងបណ្ដោះអាសន្ន វាអាចជំនួសឲ្យមុខងារនៃការព្រមានបាន។
- ផ្សេងៗ

↓

- បានបញ្ឈប់ដោយការវិសោធនកម្មច្បាប់ស្ដីការចុះបញ្ជីអចលនវត្ថុនៅឆ្នាំ2004